ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំសរុប ៤.៨១៤,៥០ ហិកតា នៅស្រុកករុទ្ធគិរី និងស្រុកភ្នំក្រវ៉ាញ ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីព្រៃនាមជូនសំ កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ កាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុនយូរីសាគរ និងកាត់ចេញពីដីសម្បទានព្រៃឬស្សី របស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ១.៤៩៧ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ



p www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/០៩៣ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៨៧ ខបប ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ដីទំហំសរុប ៤.៨១៤,៥០ ហិកតា ដែលក្នុងនោះ (១) ទំហំ ៩៩៦.៥ ហិកតា កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ (២) ទំហំ ៣.៦៨០ ហិកតា កាត់ចេញពីព្រៃរនាមដូនសំ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/០៩៣ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៣ (៣) ទំហំ ៧៨ ហិកតា កាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីសាគរ និង (៤) ទំហំ ៦០ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ៤.៨១៤,៥០ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.៩៩៧ គ្រួសារ នៅស្រុករុក្ខគិរី និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលរួមមាន៖

១.ឃុំព្រៃត្រឡាច ស្រុករុក្ខគិរី

- ផ្ទៃដីទំហំ១.០៧៤,៥០ ហិកតា ក្នុងនោះ ទំហំ ៩៩៦,៥ ហិកតា កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងទំហំ ៧៨ ហិកតា កាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុនយូរីសាគរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិស្រះថត

២.ឃុំបួរ ស្រុកភ្នំព្រឹក

- ផ្ទៃដីទំហំ១.៣៩០ ហិកតា ក្នុងនោះ ទំហំ ១.៣៣០ ហិកតា កាត់ចេញពីព្រៃរនាមដូនសំ និងទំហំ ៦០ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើ



p www.pheakdeylaw.com

អនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិបួរ

- ផ្ទៃដីទំហំ១៧៨ ហិកតា កាត់ចេញពីព្រៃរនាមជូនសំ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិដំណាក់ក្បាន្ត
- ផ្ទៃដីទំហំ១៥៨១.៥ ហិកតា កាត់ចេញពីព្រៃរនាមជូនសំ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអូរដា
- ផ្ទៃដីទំហំ ៥៩០.៥០ ហិកតា កាត់ចេញពីព្រៃរនាមជូនសំ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិភ្នំប្រាំពីរ

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) និង (២) នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១.៩៩៧ គ្រួសារ នៅស្រុករុក្ខគិរី និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលរួមមាន ៖

១.ឃុំព្រៃត្រឡាច ស្រុករុក្ខគិរី
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៨៦ គ្រួសារ នៅភូមិស្រះថត

២.ឃុំបួរ ស្រុកភ្នំព្រឹក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៥១ គ្រួសារ នៅភូមិបួរ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៣ គ្រួសារ នៅភូមិដំណាក់ក្បាន្ត
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩១២ គ្រួសារ នៅភូមិអូរដា
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៥ គ្រួសារ នៅភូមិភ្នំប្រាំពីរ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។



p

www.pheakdeylaw.com

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*



p www.pheakdeylaw.com

ឧបសម្ព័ន្ធ(១) នៃអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៣ ស្ដីពីការកាត់ដីទំហំសរុប ៤.៩១៤,៥០ ហិកតា នៅស្រុកកម្រៀង និង ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីព្រៃ[illegible] កាត់ចេញពីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ កាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន ស៊ីសារ និងកាត់ចេញពីដីសម្បទានព្រៃឬស្សី របស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.៤៩៧ គ្រួសារ




| ចំនុចនិយាមការ | | |
|---|---|---|
| ល.រ | X | Y |
| 1 | 333871 | 1389167 |
| 2 | 335937 | 1386617 |
| 3 | 335919 | 1385761 |
| 4 | 335685 | 1385258 |
| 5 | 335296 | 1384653 |
| 6 | 334907 | 1384677 |
| 7 | 334547 | 1384108 |
| 8 | 334008 | 1383802 |
| 9 | 333970 | 1384454 |
| 10 | 333601 | 1385089 |
| 11 | 332964 | 1385839 |
| 12 | 332454 | 1386284 |
| 13 | 332044 | 1386438 |
| 14 | 332188 | 1386981 |
| 15 | 332481 | 1387464 |
| 16 | 332757 | 1387350 |
| 17 | 333060 | 1388076 |
| 18 | 333085 | 1388356 |
| 19 | 333439 | 1388194 |
| 20 | 333548 | 1388374 |
| 21 | 333608 | 1388740 |
| 22 | 333553 | 1388973 |
| 23 | 333725 | 1388983 |

**ប្រព័ន្ធកូអរដោនេ :**

តំបន់ទី : 48N

ចំណោលផែនទី : UTM

ទិន្នន័យយោង : WGS1984

**ប្រភពទិន្នន័យ:**

ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ

គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២



**គម្របព្រៃឈើ**

- ព្រៃរបោះ
- ព្រៃស្រោង
- ព្រៃផ្សេងៗ
- ព្រៃពាក់កណ្ដាលស្រោង
- ដីមិនមែនព្រៃ
- ព្រំប្រទល់ដីស្នើសុំ

ឧបសម្ព័ន្ធ(២) នៃអនុក្រឹត្យលេខ ...៤៥ អនក្រ.បក... ចុះថ្ងៃទី ...១៥... ខែ ...មករា... ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំសរុប ៤.៤១៤,៥០ ហិកតា នៅស្រុករុក្ខគិរី និង ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីព្រៃនាមជួនសំ កាត់ចេញពីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ កាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន យូរីអាគារ និងកាត់ចេញពីដីសម្បទានព្រៃឫស្សី របស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.៤៩៧ គ្រួសារ




ចំនុចនិយាមការ

| ល.រ | X | Y | ល.រ | X | Y |
|---|---|---|---|---|---|
| 1 | 240647 | 1470974 | 24 | 240247 | 1466430 |
| 2 | 240697 | 1470545 | 25 | 239986 | 1466487 |
| 3 | 241548 | 1470478 | 26 | 240051 | 1466589 |
| 4 | 241425 | 1469597 | 27 | 239578 | 1466858 |
| 5 | 241518 | 1469409 | 28 | 239187 | 1466870 |
| 6 | 241251 | 1469254 | 29 | 238912 | 1466801 |
| 7 | 241378 | 1468927 | 30 | 238890 | 1467266 |
| 8 | 242552 | 1469024 | 31 | 238679 | 1467278 |
| 9 | 242448 | 1468155 | 32 | 238921 | 1469204 |
| 10 | 242636 | 1467865 | 33 | 239225 | 1469435 |
| 11 | 242817 | 1467806 | 34 | 239243 | 1469825 |
| 12 | 242638 | 1467418 | 35 | 238169 | 1469801 |
| 13 | 242279 | 1467147 | 36 | 237341 | 1470413 |
| 14 | 242029 | 1466670 | 37 | 237047 | 1470989 |
| 15 | 241970 | 1466252 | 38 | 236081 | 1471019 |
| 16 | 241986 | 1465578 | 39 | 234635 | 1470263 |
| 17 | 241799 | 1465494 | 40 | 234395 | 1470455 |
| 18 | 241551 | 1465879 | 41 | 233939 | 1470551 |
| 19 | 241338 | 1465773 | 42 | 233929 | 1470202 |
| 20 | 241179 | 1466210 | 43 | 233551 | 1470295 |
| 21 | 240911 | 1466585 | 44 | 233507 | 1477102 |
| 22 | 240575 | 1466402 | 45 | 240229 | 1471036 |
| 23 | 240333 | 1466113 | | | |